# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០១៣

## ជប៉ុនផ្តល់ ២៩,៨០៧ ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់កំពង់ចម្លង កំពង់ហៅ ខេត្តកំពង់ឆ្នាំង



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណេ) រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ២៩,៨០៧ ដុល្លាអាមេរិកដល់ក្រុមប្រឹក្សាឃុំកំពង់ហៅ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំងសម្រាប់គម្រោងសាងសង់កំពង់ផែកំពង់ហៅ ក្នុងខេត្តកំពង់ឆ្នាំង។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាថ្ងៃនេះដោយលោក ហ៊ីហ្គូជិ យ៉ូស៊ីហ៊ីរ៉ូ ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោកស្រី មាស ចាន់ថន ប្រធានក្រុមប្រឹក្សាឃុំកំពង់ហៅ នៅស្ថានទូតជប៉ុន។



ក្នុងស្រុកកំពង់លែងមានកំពង់ចម្លងបីកន្លែងដែលកំពុងត្រូវបានប្រើប្រាស់អាស្រ័យទៅតាមរដូវកាលនៃកម្ពស់ទឹកនៃទន្លេសាប ។ ជាមួយនឹងជំនួយនេះ កំពង់ចម្លងមួយដែលមានកម្រិតទាបពេកហើយមិនអាចប្រើប្រាស់បានដោយប្រសិទ្ធភាពនោះនឹងត្រូវចាក់បំពេញដីបន្ថែម ហើយផែបណ្តែតទឹកចល័តមួយដែលមានប្រវែង១០ម៉ែត្រ និងទំហំ៦ម៉ែត្រនឹងត្រូវសាងសង់ឡើង។ យើងរំពឹងថា កំពង់ចម្លងថ្មីនេះ នឹងជួយសម្រួលដល់ប្រជាជនប្រមាណ៤០,៨៨៧នាក់ដែលរស់នៅក្នុងឃុំ៩នៅក្នុងតំបន់ក្នុងការធ្វើដំណើរឆ្លងកាត់ទន្លេសាបដោយសុវត្ថិភាព។ ជាមួយគ្នានេះ វាក៏នឹងជួយសម្រួលដល់ការធ្វើដំណើរទៅកាន់មន្ទីរពេទ្យបង្អែករបស់ប្រជាពលរដ្ឋ ក៏ដូចជាជួយជំរុញសកម្មភាពសេដ្ឋកិច្ច និងការអភិវឌ្ឍតំបន់នៅជុំវិញកំពង់ផែនេះផងដែរ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណេ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និង ស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង ភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និង សេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯង

របស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៤៨.៣លានដុល្លាអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន៤៨២គម្រោងនៅទូទាំងប្រទេស។



---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ: ០២៣-២១៧-១៦១ ទូរសារ: ០២៣-២១៤-៣៣០*
*អ៊ីមែល: eco.jpn@.pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*